**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*********

**តុលាការកំពូល**

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ ៤៩

ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥

**សាលដីកា**

លេខៈ ៥០

ចុះថ្ងៃទី០៦ខែកក្កដាឆ្នាំ២០០៥

**នាមអង្គព្រះមហាក្សត្រ**

**តុលាការកំពូល**

**គោលដៅប្រជារាស្ត្រខ្មែរ**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅៈ

១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធាន

២- លោក ឈឹម ស៊ីផល ជាចៅក្រម

៣- លោក ជីវ កេង ជាចៅក្រម

៤- លោក ម៉ុង មុន្នីចរិយា ជាចៅក្រម

៥- លោក ប៉ែន សាវឿន ជាចៅក្រម-របាយការណ៍

**ក្រឡាបញ្ជី**

លោក សាន សុជាត

**តំណាងមហាអយ្យការ**

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៧"ច" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល និងសំណុំរឿងព្រហ្មទណ្ឌលេខ៤៩ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

**<u>ចំពោះ</u>:** ប្រឆាំងនឹងបទបញ្ជាសហអគ្គមេបញ្ជាការ នៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា បទសមគំនិតបង្កើតក្រុមប្រដាប់អាវុធខុសច្បាប់ និង បទឆបោក ប្រព្រឹត្តនៅក្រុងភ្នំពេញ និងតាមបណ្តាខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០២ តាមបញ្ញត្តិមាត្រា៦.៤២ ច្បាប់ស្តីពីគណបក្សនយោបាយ មាត្រា៣៦.៤៥ និង ៦៩ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ ជាម ចន្ទ័នី ( ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ កើតនៅខេត្តកំពង់ចាម របររកស៊ី តំណាងរាស្ត្រ ទីលំនៅមុនថ្ងៃចាប់ខ្លួន ភូមិភ្នំពេញថ្មី ឃុំភ្នំពេញថ្មី ស្រុកឫស្សីកែវ ក្រុងភ្នំពេញ ឪពុកឈ្មោះជាម គីម "ស"ម្តាយឈ្មោះក្រូច នីម "រ"ប្រពន្ធឈ្មោះជុំសៀង ឡេង មានកូន១នាក់ ។ ក្នុងឃុំ ។

-មានមេធាវី : លោកកែត ឃី និង លោក ម៉ៅ សុភារិទ្ធ

-តាមពាក្យបណ្តឹង ចុះថ្ងៃទី២០-៧-២០០៤ របស់នាយកដ្ឋានស្រាវជ្រាវចារកិច្ចអគ្គបញ្ជាការដ្ឋានកងយោធពល ខេមរភូមិន្ទ បានបញ្ជាក់ថា តាំងពីចុងឆ្នាំ២០០២ មក នាយកដ្ឋានស្រាវជ្រាវចារកិច្ច បានស្រាវជ្រាវរកឃើញវត្តតាងខ្លះ ដែលគណៈបក្សសមរង្ស៊ី បានលួចបង្កើតអង្គការចាត់តាំងកងទ័ព និង នគរបាល ដែលជាប្រការមួយល្មើសនឹងច្បាប់ ស្តីពីគណៈបក្សនយោបាយ និង ច្បាប់ជាធរមានផ្សេងៗ នាំឱ្យប៉ះពាល់ដល់វិស័យការពារជាតិ និង សន្តិសុខជាតិ ។ ជាក់ស្តែងនៅថ្ងៃទី៦-១២-២០០២ គណបក្សសមរង្ស៊ី បានចេញសេចក្តីសំរេចស្តីពីការតែងតាំង តាមផ្នែករបស់គណកម្មាធិការការពារជាតិ អតីតយុទ្ធជន និង កាត់បន្ថយកងទ័ព គណកម្មាធិការសន្តិសុខសាធារណៈ ដែលហៅកាត់ថា គណកម្មាធិការជំនាញទី១៤ ដែលមានឈ្មោះ ជាម ចន្ទ័នី ជាប្រធាន ហើយបានរៀបចំ រចនាសម្ពន្ធ័ តាមផ្នែក តាមថ្នាក់ផ្សេងៗ មានកងទ័ពជើងគោក កងទ័ពជើងទឹក កងទ័ពជើងអាកាស យោធភូមិភាគ គណកម្មាធិការសន្តិសុខសាធារណៈ ... ។ល។ ទន្ទឹម នឹងការរៀបចំរចនាសម្ព័ន្ធគណកម្មាធិការជំនាញទី១៤នេះ បានចាត់ចែងឱ្យជ្រើសរើសកងកំលាំងមួយចំនួន ដើម្បីចូលធ្វើជាកងទ័ព និង នគរបាលកំលាំងខ្លះ ដែលបានជ្រើសរើសរួចហើយ ពួកគេណែនាំឱ្យពាក់សក្តិទៀតផង ។ មកដល់ថ្ងៃនេះ មានប្រជាជនមួយចំនួន ដែលចាញ់បោកគណបក្សសមរង្ស៊ីក្នុងការជ្រើសរើសកងទ័ព និង នគរបាលដោយខុសច្បាប់ បានចេញមកបង្ហាញខ្លួនសារភាពជាមួយនាយកដ្ឋានស្រាវជ្រាវចារកិច្ច ហើយស្ម័គ្រចិត្តធ្វើជាសាក្សីបំភ្លឺជូនតុលាការផងដែរ ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី២៦-៧-២០០៤ របស់ឈ្មោះហេង សារី ប្តឹងពីឈ្មោះជាម ចន្ទ័នី និងឈ្មោះ ខុម ពិសិដ្ឋ ពីបទ បោកប្រាស់លុយរបស់ខ្លួនចំនួន៥០០០$ ខ្លួនសំណូមពរឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនតាមច្បាប់ ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី២៦-៧-២០០៤ របស់ឈ្មោះឡុង សើ បានប្តឹងពីឈ្មោះជាម ចន្ទ័នី និង ខុម ពិសិដ្ឋ ពីបទ ឆបោកលុយរបស់ខ្លួនចំនួន២០០$ និង លុយខ្មែរ១.១០០.០០០៛ ខ្លួនសំណូមពរឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនតាមច្បាប់ ។

-តាមពាក្យបណ្តឹងចុះថ្ងៃទី២-៨-២០០៤ របស់ឈ្មោះកែវ ស៊ីថន ប្តឹងពីឈ្មោះជាម ចន្ទ័នី ដែលបានយកលុយមួយខែចំនួន១០០.០០០៛ និង១៥០០$ ខ្លួនសំណូមពរឱ្យតុលាការជួយរកយុត្តិធម៌ និង ឱ្យជាម ចន្ទ័នី សងលុយរបស់ខ្លួនវិញ ។

-បានឃើញដីកាសំរេចលេខ០០៣ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ចៅក្រមស៊ើបអង្កេតតុលាការយោធា ដែលបានសំរេចៈ

-មិនអនុញ្ញាតិឱ្យឈ្មោះជាម ចន្ទ័នី ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរ នៅក្រៅឃុំជាបណ្តោះអាសន្ន ពីបទៈប្រឆាំងនឹងបទបញ្ជាសហអគ្គបញ្ជាការ នៃកងកំលាំងប្រដាប់អាវុធជាតិកម្ពុជា បទសមគំនិតបង្កើតក្រុមប្រដាប់អាវុធខុសច្បាប់ និងបទឆបោក ប្រព្រឹត្តនៅតាមបណ្តា ខេត្ត ក្រុងភ្នំពេញ ក្នុង

ព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០២ តាមបញ្ញត្តិមាត្រា៦.៤២ ច្បាប់ស្តីពីគណបក្សនយោបាយ មាត្រា ៣៦.៤៥.៦៩ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៤ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់លោក កែត ឃី និង លោក ម៉ៅ សុភារិទ្ធ ប្តឹងមិនសុខចិត្ត នឹងដីកាសំរេចលេខ០០៣ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ចៅក្រមស៊ើបអង្កេតតុលាការយោធា លើដីកាសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ថាៈ ករណីសុំនៅក្រៅឃុំរបស់ជនជាប់ចោទឈ្មោះជាម ចន្ទ័នី ទោះបីមានក្រុមគ្រួសារ មានទីលំនៅពិតប្រាកដ មានមុខរបរច្បាស់លាស់ក៏ដោយក៏ជនជាប់ចោទ មានបទចោទប្រកាន់ច្រើន ហើយធ្ងន់ធ្ងរ បើឱ្យជនជាប់ចោទនៅក្រៅឃុំអាចលួចរត់ទៅបរទេសតាមសង្កត់លើសាក្សី សូម្បីនៅក្នុងប្រទេស ក៏ពិបាកស្វែងរកដែរ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការស៊ើបអង្កេតរបស់តុលាការ ។ ហេតុនេះ សូមតុលាការពិចារណាតាមច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៧"ច" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់លោកមេធាវី ម៉ៅ សុភារិទ្ធ និងលោក កែត ឃី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុស នឹង គតិច្បាប់ ។

២-តម្កល់ដីកាសំរេចមិនអនុញ្ញាតិឱ្យនៅក្រៅឃុំបណ្តោះអាសន្នលេខ០០៣ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ចៅក្រមស៊ើបអង្កេតតុលាការយោធា ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង មេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខតាមកំនត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ របស់ឈ្មោះជាម ចន្ទ័នី ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១៧"ច" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៥ របស់មេធាវី កែត ឃី និង ម៉ៅ សុភារិទ្ធ ជាម្ចាស់បណ្តឹងសាទុក្ខធ្វើឡើងតាមកំណត់ច្បាប់ ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថាៈ សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវហើយ សូមតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះជាម ច័ន្ទនី ( ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលសវនាការ ថាៈ មូលហេតុដែលខ្ញុំប្តឹងសាទុក្ខមកនេះ មកពីខ្ញុំសុំនៅក្រៅឃុំ ៖

១-មានអាស័យដ្ឋានពិតប្រាកដ

២-មានអ្នកតំណាងរាស្ត្រ២១ រូបជាអ្នកធានា

៣-ខ្ញុំមានជំងឺបេះដូង

៤-ការចោទប្រកាន់មកលើរូបខ្ញុំមិនពិត ខ្ញុំមិនឆបោកគេទេ ខ្ញុំបង្កើតគណកម្មការជំនាញទី១៤ នេះ ឡើង ដើម្បីជាអ្នកនាំពាក្យពីបណ្តាអង្គភាពនានា ដូចជាផ្នែកទព័កាត់រំសាយ រោងចក្រកាត់ដេរ ក្រសួង អប់រំ .....។ល។ ដាក់ជូនរដ្ឋសភាប្រជុំ ដើម្បីដោះស្រាយឱ្យពួកគេ ។

៥-ខ្ញុំគ្មានគំនិតបង្កើតគណកម្មការជំនាញនេះ ដើម្បីប្រឆាំងនឹងរាជរដ្ឋាភិបាលទេ ខ្ញុំគ្មានអាវុធ គ្មានកងទ័ពទេ ចំណែកក្នុងប្រវត្តិរូប ដែលមានថតរូបមនុស្សពាក់សក្តិនោះ គឺក្នុងរូបភាពកាត់តទេ ។

៦-ក្នុងការតែងតាំងនេះ ត្រូវមានលក្ខខ័ណ្ឌត្រឹមត្រូវពិនិត្យមើលអំពីសមត្ថភាព ពុំមានការដោះដូរជាប្រយោជន៍នោះឡើយ ។

ដូច្នេះសូមតុលាការ ឱ្យខ្ញុំបាទនៅក្រៅឃុំផង ខ្ញុំមិនរត់គេចវេសពីតុលាការទេ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក កែត ឃី មេធាវីការពារជនជាប់ចោទឈ្មោះជាម ចន្ទ័នី (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលសវនាការ ថាៈ ខ្ញុំប្តឹងឧទ្ធរណ៍ និង ប្តឹងសាទុក្ខមកតុលាការកំពូលមកពីតុលាការ ឃុំខ្លួនកូនក្តីខ្ញុំលើស៩ខែ ៣ថ្ងៃ កូនក្តីខ្ញុំគ្មានកំហុស មិនបានប្រឆាំងបទបញ្ជាសហអគ្គមេបញ្ជាការកងទ័ពទេ ហើយក៏គ្មានការជ្រើសរើសទ័ពដែរ។ ការបង្កើតគណកម្មការនេះឡើង គ្រាន់តែជាអ្នកនាំពាក្យដាក់ជូនរដ្ឋសភា ជួយដោះស្រាយឱ្យប៉ុណ្ណោះ ។

១-កូនក្តីខ្ញុំមានអាស័យដ្ឋានច្បាស់លាស់

២-មានមុខរបរពិតប្រាកដ

៣-មានតំណាងរាស្ត្រ២១នាក់ជាអ្នកធានា

៤-មិនត្រូវបានតុលាការយោធាចោទប្រកាន់ទេ

មូលហេតុខាងលើខ្ញុំបាទសូមតុលាការកំពូលមេត្តាអនុញ្ញាតិឱ្យកូនក្តីខ្ញុំបាទបាននៅក្រៅឃុំជាបណ្តោះអាសន្ន និង សូមបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោលជាអសារបង់ ។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក ម៉ៅ សុភារិទ្ធ មេធាវីការពារជនជាប់ចោទឈ្មោះជាម ចន្ទ័នី (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលសវនាការថាៈ តាមរបាយការណ៍របស់ចារកិច្ចយោធាចោទថាគណបក្សសមរង្ស៊ីជ្រើសរើសទ័ពជើងគោក ជើងទឹកនោះ ជាការប្រឌិតឡើងទេ ព្រោះកូនក្តីខ្ញុំជាមនុស្សគ្មានកំហុស ការបង្កើតគណកម្មាការទី១៤ នេះឡើង ដើម្បីជួយ សំរបសំរួលក្នុងនាមជាអ្នកយកពត៌មានតាមជំនាញនីមួយៗ ដាក់ជូនរដ្ឋសភាជាអ្នកសំរេច ។ ម្យ៉ាងទៀតកូនក្តីខ្ញុំជាមនុស្សស៊ីវិលធម្មតា តាមមាត្រា១ ច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី មាត្រា១១ច្បាប់ព្រហ្មទណ្ឌអន្តរកាល តុលាការយោធាពុំមានសមត្ថកិច្ច ទទួលចាត់ការរឿងនេះឡើយ ព្រោះបទល្មើសនេះ ពុំទាក់ទងអ្នកប្រព្រឹត្តបទល្មើសជាយោធាទេ ព្រមទាំងមាត្រា៨ ច្បាប់រដ្ឋធម្មនុញ្ញ កូនក្តីខ្ញុំជាតំណាងរាស្ត្រសភា មិនទាន់ដកអភ័យឯកសិទ្ធិជាក់ស្តែងនៅ

មានលិខិត អញ្ជើញពីរដ្ឋសភាឱ្យកូនក្តីចូលប្រជុំនៅឡើយ តុលាការមិនត្រូវធ្វើការចាប់ឃុំខ្លួនកូនក្តីខ្ញុំទេ ដោយចំពោះបទល្មើសវិញ ពុំមែនជាបទជាក់ស្តែងដែរ ។

តុលាការកំពូលត្រូវតែដោះស្រាយ យុត្តិសាស្ត្ររបស់ខ្លួន ព្រោះជាយុត្តិសាស្ត្រផ្ទុយពីច្បាប់ ច្បាប់ពុំមានចែងថា បទឧក្រិដ្ឋមិនបានឱ្យនៅក្រៅឃុំនោះទេ កូនក្តីមានលំនៅច្បាស់លាស់ មានអ្នកធានាត្រឹមត្រូវមានជំងឺប្រចាំកាយ មានមុខរបរជាតំណាងរាស្ត្រពិតប្រាកដ គប្បីអនុញ្ញាតិឱ្យជនជាប់ចោទឈ្មោះជាម ច័ន្ទនី នៅក្រៅឃុំជាបណ្តោះអាសន្នសិន ក្នុងករណីបើតុលាការពិនិត្យថាជាពិតជាមានទោសនោះ កូនក្តីខ្ញុំសុខចិត្តមកទទួលទោសដោយខ្លួនឯង ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការ របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា: រឿងក្តីនេះមានបទល្មើសច្រើន គប្បីធ្វើការស៊ើបអង្កេតបន្ថែមទៀត ក៏វាមិនខុសច្បាប់ដែរ សូមតុលាការសំរេច ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ របស់ឈ្មោះជាម ច័ន្ទនី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទលើកឡើងនៅពេលសវនាការនេះថា តាមមាត្រា៩ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា១១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល តុលាការយោធាពុំមានសមត្ថកិច្ចជំនុំជំរះរឿងក្តីនេះទេនោះ តុលាការកំពូលពុំពិចារណាទេ ពីព្រោះថា តុលាការកំពូលជំនុំជំរះនៅពេលនេះ គឺជំនុំជំរះពីកម្មវត្ថុដែលជនជាប់ចោទសុំនៅក្រៅឃុំបណ្តោះអាសន្ន ពុំមែនជំនុំជំរះអំពីបណ្តឹងសាទុក្ខដែលមានកម្មវត្ថុទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការទេ ។

-យល់ឃើញថា ការដែលជនជាប់ចោទ និង មេធាវីជនជាប់ចោទ លើកឡើងនៅពេលសវនាការនេះថា ជនជាប់ចោទជាមនុស្សគ្មានកំហុស ដូចការចោទប្រកាន់របស់លោកព្រះរាជអាជ្ញា យោធាទេនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា រហូតដល់ពេលនេះ ជនជាប់ចោទពុំទាន់មានភស្តុតាងគ្រប់គ្រាន់សំរាប់ដោះបន្ទុកឡើយ ដោយហេតុថា ជនជាប់ចោទបានទទួលស្គាល់ថា ខ្លួនជាប្រធានគណៈកម្មការទី១៤ ដែលមានឈ្មោះថា គណៈកម្មការការពារជាតិ អតីតយុទ្ធជនកាត់បន្ថយកងទ័ព និង សន្តិសុខសាធារណៈ ។ ម្យ៉ាងទៀតនៅក្នុងសេចក្តីសំរេចស្តីពីការតែងតាំងជាច្រើន គឺសុទ្ធតែតែងតាំងឱ្យបំពេញភារកិច្ចក្នុងជួរកងទ័ព ។ម្យ៉ាងទៀត

ការឃុំខ្លួននៅពុំទាន់ហួស៦ខែផង ហើយការស៊ើបអង្កេតក៏ពុំទាន់មូលដែរ ត្រូវធ្វើការស៊ើបអង្កេតយ៉ាងច្រើន ប្រកបដោយភាពស្មុគ្រស្មាញទៀតផង ។

-យល់ឃើញថា ការដែលជនជាប់ចោទ និង មេធាវីជនជាប់ចោទ លើកឡើងនៅពេលសវនាការនេះថា ជនជាប់ចោទមានទីលំនៅពិតប្រាកដ មានការងារជាសមាជិករដ្ឋសភា មានមេធាវី និង សមាជិករដ្ឋសភាជាង២០រូប បានសុំធានាឱ្យនៅក្រៅឃុំ ដែលជាលក្ខខ័ណ្ឌអាចឱ្យជនជាប់ចោទអាចនៅក្រៅឃុំបណ្ដោះអាសន្នបានតាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនោះ ពុំទាន់ជាលក្ខខ័ណ្ឌគ្រប់គ្រាន់ទេ ពីព្រោះថា ក្នុងមាត្រា១៤ នៃច្បាប់ដដែលនេះ តុលាការពុំមានជំនឿថា ជនជាប់ចោទរូបនេះ ប្រាកដជាវិលមកបង្ហាញខ្លួន ចំពោះមុខតុលាការវិញ ដើម្បីទទួលការផ្ដន្ទាទោសពីបទឧក្រិដ្ឋឡើយ ។ ម្យ៉ាងទៀតអ្នកធានាអាចធានាបានតែលើសំណងរដ្ឋប្បវេណីប៉ុណ្ណោះ ពុំមានច្បាប់ណាចាប់បង្ខំឱ្យអ្នកធានាទទួលទោសជំនួសទណ្ឌិត ដែលបានរត់គេចខ្លួនបាត់ទេ ។

-យល់ឃើញថា ការសុំអោយជនជាប់ចោទនៅក្រៅឃុំបណ្ដោះអាសន្ន ដោយមូលហេតុសុខភាពនោះ ពុំមែនជាលក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ទេ ពីព្រោះបញ្ហាសុខភាពរបស់ពិរុទ្ធជន ឬ ទណ្ឌិត គឺជាបន្ទុកទទួលខុសត្រូវរបស់នាយកមណ្ឌល ដែលគ្រប់គ្រងពិរុទ្ធជន និង ទណ្ឌិតដែលត្រូវហៅគ្រូពេទ្យមកពិនិត្យ ឬ បញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យ ( បើសិនជាអ្នកជម្ងឺមានសភាពធ្ងន់ធ្ងរ ) ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទលើកឡើងថា តាមមាត្រា៨០ នៃរដ្ឋធម្មនុញ្ញ តុលាការពុំមានសិទ្ធិចាប់ និង ឃុំខ្លួនជនជាប់ចោទដែលជាកូនក្ដីលោកទេ ពីព្រោះពុំមានការអនុញ្ញាតិពីរដ្ឋសភា រដ្ឋសភាបានគ្រាន់តែលើកអភ័យឯកសិទ្ធិឱ្យចោទប្រកាន់ប៉ុណ្ណោះទេ នោះគឺជាការភ័ន្តច្រឡំ ពីព្រោះថា ការដែលមិនអាចចោទប្រកាន់ ចាប់ឃាត់ និង ឃុំខ្លួនសមាជិករដ្ឋសភាបាន ដោយគ្មានការអនុញ្ញាតិពីរដ្ឋសភា ឬ គណៈកម្មាធិការអចិន្ត្រៃយ៍នៅចន្លោះសម័យប្រជុំសភា មកពីសមាជិករដ្ឋសភាមានអភ័យឯកសិទ្ធិ ប៉ុន្តែនៅពេលដែលព្យួរអភ័យឯកសិទ្ធិហើយ តាមមាត្រា៣១ វាក្យខ័ណ្ឌទី២ និង មាត្រា៨៩ នៃរដ្ឋធម្មនុញ្ញជនជាប់ចោទរូបនេះមានសិទ្ធិ និង កាតព្វកិច្ច ដូចពលរដ្ឋដទៃទៀតដែរចំពោះមុខច្បាប់ ។ បានន័យថា ជនជាប់ចោទនេះ គឺត្រូវស្ថិតនៅក្រោមអំណាចនៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌដែលអាចត្រូវចោទប្រកាន់ចាប់ខ្លួន និងឃុំខ្លួនបានដូចជនប្រព្រឹត្តិបទល្មើសផ្សេងទៀតដែរ ។

-យល់ឃើញថា ការដែលមេធាវីជនជាប់ចោទលើកឡើងនៅពេលសវនាការនេះថា យុត្តិសាស្ត្រ ដែលតុលាការកំពូលកំណត់មិនឱ្យជនជាប់ចោទពីបទឧក្រិដ្ឋនៅក្រៅឃុំបណ្ដោះអាសន្ន ជាយុត្តិសាស្ត្រមួយផ្ទុយនឹងច្បាប់ នោះគឺជាការភន្តច្រឡំ ពីព្រោះថា តាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល បានបញ្ជាក់ថា កាលណាមានការបារម្ភថា ខ្លាចជនជាប់ចោទរត់គេចខ្លួន នឹងគ្មានអ្វីអាចធានាថា ជនជាប់ចោទប្រាកដជាវិលមកបង្ហាញខ្លួន នៅតុលាការវិញទេ តុលាការអាចឃុំខ្លួនបណ្ដោះអាសន្នបាន៦ខែ ។ តុលាការកំពូលកំណត់ថា ចំពោះបទឧក្រិដ្ឋ បើអនុញ្ញាតិអោយនៅក្រៅឃុំ ពុំមានទណ្ឌិតណាត្រឡប់មកទទួលទោសឧក្រិដ្ឋរបស់ខ្លួននៅមុខ

តុលាការវិញទេ ។ ដូច្នេះក្នុងរយៈពេលឃុំខ្លួនបណ្តោះអាសន្ន៦ខែនេះ តុលាការកំពូលពុំអនុញ្ញាតិឱ្យនៅក្រៅឃុំឡើយ យុត្តិសាស្រ្តនេះពុំមានខុសនឹងច្បាប់ណាទាំងអស់ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៧"ច"ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខជាស្ថាពរ**

១-ទទួលបណ្តឹងសាទុក្ខលេខ៩៧ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ របស់ឈ្មោះ ជាម ចន្ទ័នី ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៧"ច" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ៤៩ ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅតុលាការយោធា ដើម្បីចាត់ការរឿងអង្គសេចក្តី ។

៤-សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៥ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៥ ។ ៚